**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**

លេខ ០៨១៥/២៤ អគរ

ថ្ងៃ ច័ន្ទ ២ រោច ខែ មាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៤

# សេចក្ដីជូនដំណឹង

## ស្ដីពី

## ការដាក់ឱ្យអនុវត្តជំហានដំបូងនីតិវិធីបំពេញបែបបទគយមុនពេលទំនិញមកដល់ នៅសាខាគយនិងរដ្ឋាករកំពង់ផែអន្តរជាតិក្រុងព្រះសីហនុ

អនុលោមតាមប្រកាសលេខ ១៤៤៧ សហវ.ប្រក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០៧ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ដីពីបញ្ញត្តិនិងនីតិវិធីប្រតិវេទន៍គយ និងប្រកាសលេខ ៧៨៨ សហវ.ប្រក.អគរ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ដីពីនីតិវិធីបំពេញបែបបទគយមុនពេលទំនិញមកដល់ និងក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងថែមទៀតនូវកិច្ចសម្រួលពាណិជ្ជកម្ម អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា សម្រេចដាក់ឱ្យអនុវត្តជំហានដំបូងមុខងារសម្រាប់ការរាយការណ៍អំពីទំនិញមុនពេលទំនិញមកដល់តាមមធ្យោបាយអេឡិចត្រូនិក តាមរយៈតំណភ្ជាប់ https://asyhub.customs.gov.kh និងអនុញ្ញាតឱ្យអនុវត្តនីតិវិធីដាក់ប្រតិវេទន៍គយមុនពេលទំនិញមកដល់ នៅសាខាគយនិងរដ្ឋាករកំពង់ផែអន្តរជាតិក្រុងព្រះសីហនុ ចាប់ពីថ្ងៃទី១ ខែមីនា ឆ្នាំ២០២៤ តទៅ។

អាស្រ័យហេតុនេះ សូមសាធារណជន ប្រតិបត្តិករដឹកជញ្ជូនទំនិញ ប្រតិបត្តិករបញ្ជូនទំនិញ ប្រតិបត្តិករនាវាភាវវេទកិច្ច អ្នកនាំចូល ជើងសាគយ និងអ្នកពាក់ព័ន្ធ ជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**

**អគ្គនាយកគយនិងរដ្ឋាករកម្ពុជា**

បណ្ឌិត គុណ ញឹម

**ចម្លងជូន÷**

- ខុទ្ទកាល័យឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ "ដើម្បីគោរពជូនជ្រាប"
- សភាពាណិជ្ជកម្មកម្ពុជា
- សមាគមភស្តុភារកម្មកម្ពុជា
  "ដើម្បីជ្រាប និងសហការផ្សព្វផ្សាយ"
- គ្រប់អង្គភាពគយនិងរដ្ឋាករពាក់ព័ន្ធ "ដើម្បីជ្រាបនិងអនុវត្ត"
- ឯកសារ កាលប្បវត្តិ